**monashwomens.org**

ភាសាខ្មែរ (Khmer/Cambodian)

# ការសំរាលទារក (Giving Birth)

## តើអ្វីដែលគិតទុកជាមុន នឹងតើអ្វីអ្នកអាចធ្វើបាន

## (What to expect and what you can do)



MonashWomen's

MonashHealth

## មាតិកា (Contents)


3. ការរៀបចំសំរាប់ពេលឈឺពោះសំរាលនឹងពេលសំរាលទារក

4. សញ្ញាផ្សេងៗនៃការឈឺពោះសំរាលទារក

5. ការជូសបំបែកទឹកភ្លោះ ជួយឲ្យឈឺពោះសំរាលទារក

6. ការឈឺពោះសំរាលទារក នឹងការសំរាលទារក

7. អ្នកអាចស្វែងយល់ថាជាការសំរាកដ៏ងាយស្រួល

8. វិធីប្រើនូវប្រដាប់ផ្សេងៗជួយបន្ថយការឈឺចុកចាប់

9. ការចាក់ម្ជុលបញ្ចូលថ្នាំស្ពឹកទៅក្នុងខួរឆ្អឹងខ្នង

10. ប្រដាប់គៀបនឹងប្រដាប់បូមក្បាលទារកជួយនៅពេលសំរាល

11. ការវះកាត់លើផ្ទៃពោះ ដើម្បីជួយសំរាលទារកជាបន្ទាន់

12. តើខ្ញុំអាចគិតថានៅពេលវះកាត់ផ្ទៃពោះជួយសំរាលទារកយ៉ាងណាដែរ?

13. ការថតរូប

14. ប្រព័ន្ធនៃកំរិតការប្រម៉ាណពីស្ថានភាពទៅលើរូបរាងកាយទារកទើបកើត

15. ការចាប់ផ្តើមជាដំបូង ពេលឈឺពោះសំរាលទារក

16-17 សកម្មភាពឈឺពោះសំរាលទារក

18. បន្ទាប់ពីសំរាលរួច




monashwomens.org

- លិខិតប័ណ្ណផ្តល់ជូនពីឆ្មបរបស់អ្នក ឬពីវេជ្ជបណ្ឌិត បើអ្នកគិតពិចារណាថាផ្ទៃកសិរិវិទ្យានៅក្នុងសំណាក់ការទី3។ ដោយមិនបាច់ចាក់ថ្នាំនៅក្នុងដំណាក់ការទី 3 ពេលឈឺពោះសំរាល ដែលតែងមានយ៉ាងតិចណាស់ពី 2 ទៅដល់ 60 នាទី។
- ចូរទំរេតដងខ្លួនឲ្យបានត្រង់ អាចជួយឲ្យរាងកាយអ្នកជម្រុញសុកធ្លាក់ចេញ។
- ការធ្លាក់ឈាមតិចតួច គឺតែងមានមុនពេលសុកធ្លាក់ចេញ។

## ❖ បន្ទាប់ពីសំរាលទារករួច ( After the birth)

- កស្បូនអ្នកបិទវិញបន្ទាប់ពីសុកនឹងកន្សោមភ្នាសរុំទារកបានទម្លាក់ចេញផងដែរ។
- ពេលលើកដំបូង ទារករបស់អ្នកនឹងត្រូវបានដាក់ផ្ទប់ស្បែកទៅនឹងស្បែកម្តាយ ( លុះត្រាតែអ្នកមិនចង់ធ្វើដូចនេះ)។
- អ្នកមានអារម្មណ៍ “ ឈឺបន្ទាប់ពីសំរាលទារករួច ”ដោយសរសៃសាច់ដុំក្បាលពោះគឺមកពីស្បូនកន្ទាក់រឹតខ្លាំង។
- ឆ្មបរបស់អ្នកតាមពិនិត្យមើលដោយទៀងទាត់ដល់រូបអ្នក នឹងទារករបស់អ្នក។
- អ្នកនឹងបានទទួលជំនួយក្នុងការជួយបំបៅដោះដល់ទារកអ្នក។
- រយះពេល 2-3 ថ្ងៃ អ្នកមានធ្លាក់ឈាមតាមទ្វារមាសច្រើនដូចជាឈាមរដូវ។
- អ្នកអាចមានអារម្មណ៍អស់កម្លាំងខ្លាំងក្រោយពីបទពិសោធន៍ដ៏អស្ចារ្យនេះដោយអ្នកខំប្រឹងប្រែងដើម្បីឲ្យទារកអ្នកបានសំរាលចេញមកនៅក្នុងពិភពលោកនេះ។
- អ្នកបានទទួលការសំរាកយ៉ាងល្អ រួមមានអាហារសម្រន់នឹងទឹកភេជ្ជះរួមផង។

សូមផ្តល់ការកោតសរសើដល់អ្នក !



## ❖ ការរៀបចំសំរាប់ពេលឈឺពោះសំរាល នឹងពេលសំរាលទារក

**(Preparing for labour and birth)**

- កិច្ចការមួយចំនួនដែលអ្នកមានចិត្តចង់ធ្វើ
- អ្នកគួរគិតដោយម៉ត់ចត់ចំពោះមិត្តភ័ក្រនឹងក្រុមគ្រួសាររបស់អ្នក ដោយមានអ្នកណាខ្លះគេអាចជួយគាំទ្រដល់រូបអ្នកនៅពេលសំរាលទារកនេះ។ យើងសូមស្នើដល់អ្នកឲ្យយកអ្នកជួយគាំទ្របានតែពីរនាក់ប៉ុណ្ណោះ។
- អ្នកគួរចាត់ចែងពេលវេលាចូលរួមក្នុងវគ្គសិក្ខាសាលា សំរាប់ការសំរាលទារករួមភារះកិច្ចជាឪពុកម្តាយ នឹងវគ្គសិក្សារមួយចំនួន នៅពេលជាលើកដំបូងទៀតផង។
- អ្នកគួរអាននៅក្នុងទំព័រ www.monashwomens.org ដោយមានបង្ហាញពីសេវាបំរើនៅក្នុងមន្ទីរសម្ភព មានពត៌មានដ៏ទៃទៀតដែលអាចជួយអ្នកបានដូចមាននៅក្នុងសលាកប័ត្ត “Fact sheets”។
- ចូរពិភាក្សាជាមួយឆ្មប នឹងវេជ្ជបណ្ឌិតរបស់អ្នកពីផលល្អនឹងផលមិនល្អដោយប្រើនូវវិធីផ្សេងៗ ជាជំនួយជួយបំបាត់ការឈឺចុកចាប់នៅពេលឈឺពោះសំរាលទារក។
- ចូរពិភាក្សានឹងអ្នកជួយគាំទ្រ វេជ្ជបណ្ឌិត ឬឆ្មបពីបំណងសំរាប់ការថែទាំដល់អ្នក។
- ចូរនិយាយជាមួយវេជ្ជបណ្ឌិតរបស់អ្នកពីភាពទុក្ខកង្វល់ដែលអ្នកមានខ្លះៗ
- ចូររៀបចំកាបូបសំរាប់ពេលអ្នកស្នាក់នៅមន្ទីរពេទ្យរវាងប៉ុន្មានសប្តាហ៍ មុនថ្ងៃដែលអ្នកសំរាលទារក( សូមអាន “Fact sheets“ តើអ្វីខ្លះដែលត្រូវយកទៅមន្ទីរពេទ្យ?។
- គួរស្វែងយល់ថាតើគួរធ្វើយ៉ាងណា នៅពេលអ្នកគិតថាអ្នកមានការឈឺពោះសំរាលទារកហើយ តើទីកន្លែងណាដែលត្រូវទៅ ? ។
- លេខទូរស័ព្ទខ្លះមាននៅ " ប័ណ្ណសំរាប់ទាក់ទង = Contacts Card “ របស់អ្នក។ ចូររក្សារទុកប័ណ្ណនេះសំរាប់ងាយស្រួលរកគ្រប់ពេលវេលា។
- ចូរប្រុងប្រយ័ត្នថា ពេលខ្លះអ្វីៗមិនអាចទៅតាមគម្រោងការណ៍ ជានិច្ចនោះឡើយ ប៉ុន្តែមិនថាឡើយ មានហេតុកើតឡើង នោះអ្នកនៅតែមានភាពជួយគាំទ្រជាដ៏រាប។

- ## សញ្ញាផ្សេងៗ នៃការឈឺពោះសំរាលទារក (Signs of Labour)

ពេលខ្លះមានការលំបាកក្នុងការយល់ដឹង បើការឈឺពោះសំរាលពិតជាចាប់ផ្តើមហើយ។ សញ្ញាខ្លះៗចាប់ផ្តើមមានឡើង នឹងអាចបាត់ទៅវិញ នៅពេលមួយថ្ងៃ ឬពីរថ្ងៃមុនពេលដែលលំនាំក្នុងការឈឺចាប់បានផ្តើមឡើងយ៉ាងទៀងទាត់។

អ្នកអាចមានសន្ទុះនៃកម្លាំងថាមពលរហូតដល់ទីបញ្ចប់នៃការមានផ្ទៃពោះ ឬអ្នកមានអារម្មណ៍ព្រួយអន្ទះសារ ដោយមិនអាចនៅសំរាកស្ងៀមបាន។

- ### ភាគច្រើនសញ្ញាដែលតែងមានជាធម្មតាពេលចាប់ផ្តើមឈឺពោះគឺមាន៖

- ការឈឺពោះរឹតកន្ត្រាក់កើតមានឡើងជាទៀងទាត់ ញឹកញាប់ រួមគ្នា ពេលវេលាឈឺពោះដ៏យូរហើយកាន់តែខ្លាំងឡើងៗ។
- ការធ្លាក់ Show ជាសន្ទះរំអិលខាប់នៅមាត់ស្បូនធ្លាក់ចេញដោយគ្មានភាពឈឺចាប់។ គឺអាចមានជាឈាមប្រឡាក់។ អ្នកតែងតែស្វែងយល់នៅពេលអ្នកមានធ្លាក់ Show នៅពេលអ្នកទៅបង្គន់។
- ការបែកទឹកភ្លោះ (បែកថង់ភ្នាសស្រោបទារក)។ អ្នកអាចបែកធ្លាយនូវទឹកភ្លោះ (ទឹកដែលនៅជុំវិញទារក) ឬអ្នកមានលេចជ្រាបបន្តិចៗ រួមគ្នាតែម្តងនោះ។ គឺអាចកើតមានមុនពេលអ្នកមានអារម្មណ៍ឈឺពោះរឹតកន្ទាក់ៗ។
- អ្នកមានឈឺចង្កេះ ឈឺខ្នង
- ចលនាឈឺពោះ បត់ជើងរាគ

- ### ពេលណាខ្ញុំគួរទូរស័ព្ទទៅកាន់មន្ទីរពេទ្យ ? (When should I ring the Hospital?)

- បើអ្នកគិតថាមានលេចជ្រាបទឹកភ្លោះ (បែកថង់ភ្នាសស្រោបទារក)
- បើអ្នកមានការឈឺពោះរឹតកន្ត្រាក់ជាទៀងទាត់រវាង 5 នាទីម្តងៗ
- បើអ្នកមានធ្លាក់ឈាម(ច្រើនជាងឈាមរំអិលធ្លាក់)
- បើអ្នកមានអារម្មណ៍ក្នុងភាពព្រួយបារម្ភ
- បើអ្នកមានអារម្មណ៍ចំពោះទារកមិនកម្រើកក្នុងរយៈពេល 2 ម៉ោង ឬចលនាកម្រើកមានតិចតួចខុសពីភាពធម្មតា។

ពេលអ្នកទូរស័ព្ទទៅមន្ទីរពេទ្យផ្នែកមន្ទីរសម្ភព នោះឆ្មបនឹងសាកសួរមកអ្នកនូវសំនួរមួយចំនួនដោយផ្តល់នូវឱវាទថាតើធ្វើអ្វីជាបន្ទាប់ទៅនេះ។



## ❖ សកម្មភាពពេលឈឺពោះសំរាល- ក្នុងដំណាក់ការទី ២( Active labour- second stage)

- នៅដំណាក់ការទី២ ពេលឈឺពោះសំរាលទារក តែងមានរយៈពេលពី 1- 2 ម៉ោង សំរាប់ទារកដំបូងរបស់អ្នក ហើយសំរាលកាន់តែឆាប់ បើអ្នកធ្លាប់មានទារកពីមុន
- ឈឺពោះរឹតកន្ត្រាក់ខ្លាំងឡើងៗជិតសំរាល ព្រមកម្លាំងខ្លាំងដើម្បីរុញទារកចេញ។
- កស្បូនបានយ៉ាងបើកពេញសន្ទឹង
- បើសិន កស្បូនមិនទាន់បើក ដូច្នេះទឹកភ្លោះនឹងបែកមុនពេលទារករបស់អ្នកសំរាល
- បឺតសារធាតុរាវអាចជួយ បើអ្នកស្ងួតមាត់
- ឆ្មបរបស់អ្នកនឹងស្តាប់សង្វាក់បេះដូងទារករាល់ពេល 5 នាទីម្តង
- អាចជួយដោយចលនាក្នុងការផ្លាស់ប្តូរទម្រង់ប្រែប្រួល
- ឆ្មបនឹងដៃគូរបស់អ្នកនឹងជួយលើកទឹកចិត្តអ្នកឲ្យខំជម្រុញទារកកើតចេញមក
- អ្នកអាចផ្តោតអារម្មណ៍យ៉ាងខ្លាំងទៅលើកការខិតខំប្រឹងប្រែងរបស់អ្នក
- ឆ្មបរបស់អ្នកនឹងជួយគាំទ្រដល់អ្នក ដោយនៅជាមួយអ្នក នឹងជួយអ្នកឲ្យផ្តោតទៅលើដំណាក់ការចុងក្រោយមុនពេលទារករបស់អ្នកសំរាល។

## ❖ ពេលឈឺពោះសំរាលទារក -ក្នុងដំណាក់ការទី ៣ ( Active labour- third stage)

- នេះគឺជាពេលចាប់ពីពេលសំរាលទារក ទល់ដល់ពេលទម្លាក់សុក
- " សកម្មភាពផ្នែកគ្រប់គ្រង " នេះបានស្នើផ្តល់ជូនដើម្បីបន្ថយនូវភាពហានិភ័យដល់អ្នកពីការធ្លាក់ឈាមយ៉ាងច្រើន បន្ទាប់ពីសំរាលទារករួច។
- ចំពោះ " សកម្មភាពផ្នែកគ្រប់គ្រង " អ្នកបានទទួលនូវការចាក់ថ្នាំហៅថាអ៊ុកស៊ីតូស៊ីក (Oxytocic) បន្ទាប់ពីអ្នកសំរាលទារកហើយភ្លាម។ ថ្នាំអ៊ុកស៊ីតូស៊ីកធ្វើឲ្យស្បូនកន្ត្រាក់ជួយឲ្យសុកឆាប់ធ្លាក់ចេញមក។
- " សកម្មភាពផ្នែកគ្រប់គ្រង " តែងតែបន្ថយរយៈពេលនៅដំណាក់ការទី 3 នៃការឈឺ
- ពោះសំរាលដោយមានជាមធ្យមក្នុងរយៈពេល 5- 15 នាទី នៃការទម្លាក់សុក។
- ភាពគ្រប់គ្រងផ្នែកសិរិវិទ្យាគួរតែគិតពិចារណាសំរាប់តែស្ត្រីណា ដែលជាអ្នកមិនដែលធ្លាប់ពិបាកស្មុគស្មាញពេលមានផ្ទៃពោះនឹងពេលសំរាលទារក។
- អ្នកអាចមានធ្លាក់ឈាមរំអិលពណ៌ផ្កាឈូក (Show) ។ គឺជារំអិលផ្ទុកបិទនៅមាត់កស្បូនរបស់អ្នក អាចមានប្រឡាក់ឈាម។ ទឹកភ្លោះអ្នកនឹងបែកធ្លាយដែរ។

## • សកម្មភាពឈឺពោះសំរាលទារក-ក្នុងដំណាក់កាល ទី ១ ( Active labour- first stage)

- អ្នកបានទទួលដំបូន្មានឲ្យទាក់ទងទៅកាន់មន្ទីរពេទ្យនៅដំណាក់ការនេះ
- សកម្មភាពនៅក្នុងដំណាក់ការឈឺពោះដំបូង ជាមធ្យមដល់ទៅ 8 ម៉ោង ហើយមិនទំនងអាចឈឺយូរលើសពី 18 ម៉ោងឡើយ។
- ដំណាក់ការទី ២ ឈឺពោះមានបន្តបន្ទាប់ជាមធ្យមដល់ទៅ 5 ម៉ោង ហើយមិនទំនងអាចឈឺយូរលើសពី 12 ម៉ោងឡើយ។
- ការឈឺពោះរឹតកន្ត្រាក់មានជាញឹកញាប់រាល់ពេល 2 -3 នាទីម្តង ដោយមិនឈឺលើសពី 60 វិនាទីឡើយ។
- ចូរពិសារសារធាតុរាវគឺអាចជួយបាន។ អ្នកមានអារម្មណ៍មិនចង់ញុាំអ្វី
- ដោយឈរដើរត្រង់ខ្លួន ជាសកម្មភាពមួយអាចជួយមិនចាប់បាច់ជំនួយភាពបំបាត់ការឈឺចុកចាប់នឹងធ្វើឲ្យដំណាក់ការឈឺពោះសំរាលដំបូងមិនសូវឈឺយូរ។
- ឆ្មបមើលថែអ្នកពេលឈឺពោះសំរាលទារក។ ជាញឹកញាប់ ឆ្មបស្តាប់ចង្វាក់បេះដូងដល់ទារក ការវាស់កម្តៅ សម្ពាធឈាម ស្វាបជីពចរដល់អ្នក។ ឆ្មបពិនិត្យឈាមធ្លាក់ពីទ្វារមាសរបស់អ្នក។
- ឆ្មបរបស់អ្នកនឹងស្នើប្តូរទម្រង់កន្លែងគេង ឬជម្រើសផ្សេងៗដើម្បីជួយអ្នកសម្របទៅភាពមិនសុខស្រួលនៅពេលឈឺពោះសំរាលទារកនេះ។
- បើសិនជាអ្នកសួររកមានថ្នាំជំនួយសំរាប់បំបាត់ការឈឺចាប់មានផ្តល់ឲ្យពី ឆ្មបរបស់អ្នករួមដោយពិភាក្សាពីភាពទាំងនេះផងដែរ។
- កស្បូនរបស់អ្នកចាប់បើកបន្តិចម្តងៗរហូតដល់ 10 សង្ទីម៉ែត្រ
- ជាទីបញ្ចប់នៅដំណាក់ការដំបូង អ្នកហាក់បីដូចជាមានភាពអារម្មណ៍រំជួលចិត្ត ឬមានភាពមួរម៉ៅ ឬប្រហែលជាអន្ទះអន្ទែងជាមួយអ្នកជួយគាំទ្រ។ អ្នកអាចមានអារម្មណ៍មិនអាចអត់ធន់បាន។ គឺជាសញ្ញាដ៏ល្អមួយ ដែលអ្នកជិតដល់គោលដៅហើយ ( ដល់ពេលទារកសំរាល)។



➢ សំនួរមួយចំនួនដែលឆ្មបអាចសួរទៅអ្នកគឺមាន៖

- តើពេលឈឺពោះសំរាលទារករបស់អ្នកពីពេលទារកមុនមានរយះយូរប៉ុណ្ណាដែរ?
- តើអ្នកនៅឆ្ងាយពីមន្ទីរពេទ្យដែរ?
- តើអ្នកមានអារម្មណ៍ បែបយ៉ាងណា នឹងតើអ្នកចង់ធ្វើយ៉ាងណាដែរ?
- តើអ្នកមានឈឺចាប់ដែរ? អ្នកមានបែកទឹកភ្លោះដែរ? ទារករបស់អ្នកកំរើកបំរាស់ច្រើនជាធម្មតាដែរ? ឬអ្នកមានធ្លាក់ឈាមដែរ? (ការផ្លាស់ប្តូរគឺជាភាពដ៏សំខាន់)។

## • ការជួសបំបែកទឹកភ្លោះជួយឲ្យឈឺពោះសំរាលទារក (Induction od labour)

ការជួសបំបែកទឹកភ្លោះជួយឲ្យឈឺពោះសំរាលទារក គឺជាដំណើការផ្នែកវេជ្ជសាស្រ្តដោយបានប្រើឲ្យចាប់ផ្តើមឈឺពោះសំរាលទារក។

ភាគច្រើនការមានផ្ទៃពោះ គឺជាភាពដ៏ល្អបំផុត បើការចាប់ផ្តើមឈឺពោះសំរាលដោយភាពជាធម្មជាតិ។ ការជួសបំបែកទឹកភ្លោះជួយឲ្យឈឺពោះសំរាល នឹងមានការពិភាក្សាដោយស្នើជូនអ្នក នៅពេលការមានផ្ទៃពោះបានហួសកំណត់ថ្ងៃកើត គឺអាចមានជាគ្រោះថ្នាក់ខ្លាំងជាងការជួសបំបែកទឹកភ្លោះជួយឲ្យឈឺពោះសំរាលទារកទៅទៀត។

មូលហេតុមានមួយចំនួន គឺហេតុអ្វីបានជាការជួសបំបែកទឹកភ្លោះជួយឲ្យឈឺពោះសំរាលអាចត្រូវបានស្នើសុំឲ្យធ្វើដូច្នេះ ៖

- ការមានផ្ទៃពោះនៅបន្តហួសកំណត់ថ្ងៃទារកកើត
- បែកថង់ទឹកភ្លោះជាភ្នាសស្រោបទារក ដោយភ្លាមៗ គ្មានការឈឺពោះសំរាល
- ការលើសសម្ពាធឈាមខ្លាំង
- រោគទឹកនោមផ្អែម ភាពសង្ស័យពីការលូតលាស់របស់ទារកមានភាពចុះកំរិតទាប

ចំពោះស្រ្តីមានភាពលក្ខណះបែបទាំងនេះ គឺបានគិតពីការជួយជួសបំបែកទឹកភ្លោះឲ្យឈឺពោះសំរាល ។ ភាពនេះគ្មានហានិភ័យដល់ម្តាយនឹងទារកឡើយ ជាជាងទុកផ្ទៃពោះហួសកំណត់ថ្ងៃកើត នេះជាមូលហេតុសំរាប់ការជួសបំបែកទឹកភ្លោះជួយឲ្យឈឺពោះសំរាលទារក។ មន្ទីរពេទ្យម៉ូណាស់មិនបានស្នើឲ្យធ្វើការជួសបំបែកទឹកភ្លោះដើម្បីសំរាលទារក ពេលហួសកំណត់ថ្ងៃកើតនោះឡើយ គឺទាល់តែការមានផ្ទៃពោះនេះនៅបន្តហួសយ៉ាងតិចណាស់ពី 10 ទៅ 14ថ្ងៃ លើសពីថ្ងៃកំណត់ដែលត្រូវកើត។

ពត៌មានដ៏ជាក់លាក់ស្តីពី ការជួសបំបែកទឹកភ្លោះ ជួយឲ្យឈឺពោះសំរាលទារកបានផ្តល់ឲ្យពីវេជ្ជបណ្ឌិតរបស់អ្នក បើគេបានគិតថានឹងត្រូវធ្វើការជួសបំបែកទឹកភ្លោះ។

## ❖ ការឈឺពោះសំរាល នឹងការសំរាលទារក ( Labour and Birth)

ការឈឺពោះសំរាល នឹងការសំរាលទារកគឺជាការងារដ៏លំបាកមួយ មានភាពដូច ជាការរត់ប្រណាំងយកចំងាយដែរ។ ការឈឺពោះសំរាលទារក ត្រូវតែខិតខំដោយ កម្លាំងប្រឹងប្រែង គឺអាចនឹងមានដំណើ ការយ៉ាងយូរដល់រូបរាងកាយ ប៉ុន្តែអាចដឹង អំពីដំណើការដែលអាចត្រូវការជំនួយសំរាប់ជួយ។

ការឈឺចុកចាប់ដោយមកពីការឈឺពោះសំរាលទារកនេះមិនបង្ហាញថាជាភាពវង្រោះ នោះឡើយ តែដូចគ្នាដោយយើងមានបទពិសោធន៍ដោយភាពឈឺចុកចាប់យ៉ាងខ្លាំង ។ គឺជាសញ្ញាដែលរូបរាងកាយរបស់យើងធ្វើការយ៉ាងលំបាកខ្លាំងដើម្បីសំរាលទារកឲ្យ បានចេញមកក្នុងពិភពលោកនេះ។

មានភាពផ្សេងៗមួយចំនួនដែលអ្នក ឬ អ្នកជួយគាំទ្រដល់អ្នក នឹងអ្នកថៃទាំរបស់អ្នក ពួកគេអាចជួយនៅពេលអ្នកឈឺពោះសំរាលទារក ។

ដោយមានការលើកទឹកចិត្ត នឹងអ្នកជួយគាំទ្រផ្តល់ការថ្នាក់ថ្នមលួងលោមដល់អ្នក នេះគឺជាភាពដ៏សំខាន់ផងដែរ។

### ❖ តើអ្នកត្រូវធ្វើដូចម្តេច?

- ចូរសំរាករាងកាយនៅចន្លោះពេល នឹងនៅរាល់ពេលឈឺពោះរឹតកន្ត្រាក់ម្តងៗ
- ចូរញុាំនូវសារជាតុរាវឲ្យទៀងទាត់នៅចន្លោះពេលឈឺម្តងៗ គឺអាចជួយ ការពារពីកង្វះជាតិទឹក នឹងការបាត់បង់ថាមពល
- ចូររក្សាគ្រោងការផ្ទង់សតិអារម្មណ៍ក្នុងភាពជាវេជ្ជមាន
- ចូរប្រើនូវភាពវេជ្ជមានផ្សេងៗនៅពេលឈឺពោះសំរាលទារក នេះមានដូចជា៖
- ការឈ
- ការដើរ
- ការគេងទំរេតដោយចំហៀងខ្លួន
- ការលុតជង្គង់
- ការផ្អែកទ្រោបទៅលើដៃគូ ឬអ្នកគាំទ្រ ឬលើស្បោងធំទន់ៗ ( Bean bag )
- ការអង្គុយចោងហោង

ឆ្អឹងរបស់អ្នកអាចស្មើក្នុងការសាកល្បងពីទម្រង់ផ្សែកៗ ពេលដែលអ្នកមានដំណើរ ការឈឺពោះសំរាលទារកនេះផងដែរ។





### ❖ ការចាប់ផ្តើមជាដំបូង ពេលឈឺពោះសំរាលទារក ( Very early labour)

- ពេលចាប់ផ្តើមជាដំបូង ភាពមិនច្បាស់លាស់ ដែលគួរឲ្យកំណត់ថាជាការឈឺពោះ សំរាលទារក។ ចំពោះម្តាយៗ កូនដំបូងការប៉ាន់ប្រមាណ ពេលឈឺពោះសំរាល ប្រហែលជា 12 ម៉ោង ( ប៉ុន្តែអាចយ៉ូរដល់ទៅ 20 ម៉ោងផង) ចំពោះស្ត្រីដែលធ្លាប់ សំរាលទារកជាបន្តបន្ទាប់មក គឺការសំរាលអាចមានរយះពេលតែ 6 ម៉ោង ។
- អ្នកមានអារម្មណ៍មិនសុខស្រួលពេលអ្នកឈឺពោះរឹតកន្ត្រាក់ ប៉ុន្តែការឈឺសំរាលនៅ មិនទាន់ទៀងទាត់នៅឡើយ។
- ចូរញុាំអាហារ នឹងញុាំទឹក តាមអារម្មណ៍ដែលអ្នកអាចចង់ញុាំបាន
- ចូរចំណាំមើលទៅលើការកម្រើករបស់ទារកអ្នក។ បើអ្នកមិនមានអារម្មណ៍ពីទារក អ្នកកម្រើកក្នុងពេលរយះពេល 2 ម៉ោង ឬចលនាក្នុងការកម្រើកមានកាន់តែតិចតួចជាង ពីភាពធម្មតា សូមទាក់ទងទៅកាន់មន្ទីរពេទ្យភ្លាម។
- ការដើរ ឬការពត់ខ្លួនប្រាណអាចជួយអ្នកឲ្យមានភាពសម្រួលអារម្មណ៍បាន
- អ្នកដូចជាមិនចង់នៅតែម្នាក់ឯង អ្នកជួយគាំទ្រ ឬដៃគូរ របស់អ្នកជួយកាន់ទប់អ្នក ដោយជួយរឹតរូតខ្នងឲ្យអ្នក នឹងគេជួយអះអាងលើកទឹកចិត្តដល់អ្នកផងដែរ។
- កស្បូនរបស់អ្នកបានបើក ហើយឡើងទន់ស្តើង។
- ការងូតទឹក ការដើរទៅមកជុំវិញ ការធ្វើសរសៃ ការលំហែអារម្មណ៍ស្តាប់ភ្លេង លេបថ្នាំប៉ារាសេតាម៉ុលអាចជួយបាន (មិនឲ្យលើសពី 4g ក្នុងរយះពេល 24 ម៉ោង)។
- អ្នកអាចមានចិត្តរំភើប តែជម្រុញចិត្តខ្លួនឯង បើសិនជាអាចសំរាកឲ្យបានច្រើន។

### ❖ ប្រព័ន្ធនៃកំរិតការប្រមាណពីស្ថានភាពទៅលើរូបរាងកាយទារកទើបកើត

ពី 1 ទៅ 5 នាទីពេលទារកទើបសំរាល ឆ្មបឬវេជ្ជបណ្ឌិតនឹងឆែកមើលទារកអ្នកពី ការដកដង្ហើម ចង្វាក់បេះដូង ពណ៌សម្បុរ កន្ត្រាក់សាច់ដុំដោយចលនាផ្សេងៗ។ ប្រព័ន្ធកំរិត នឹងបានធ្វើដោយស្វ័យប្រវត្តិជូន ដោយអ្នកមិនបានជាគិតពីអ្វីដែលគេបាន ធ្វើនោះឡើយ។ ការឲ្យកំរិតផ្តល់ឲ្យពីប្រភេទនិមួយៗចាប់ពីលេខ 0 ទៅ 1 ឬ 2 បើចំនួន ចាប់ពី 7 ឡើងទៅ គឺគេបានចាត់ថាជាភាពបានល្អហើយ។ បើប្រព័ន្ធកំរិតទាប ខ្លាំងមាន ន័យថាទារកពិតជាត្រូវការផ្នែកថៃទាំពីវេជ្ជសាស្ត្រជាបន្ទាន់។

### ❖ ឈាមមានកំរិតជាតិស្ករពីទងសុក (Cord blood lactate levels)

កំរិតជាតិស្ករមាននៅក្នុងឈាមបានពីទងផ្ចិតទារកអាចផ្តល់ពត៌មានឲ្យយើងដឹងពី សុខភាពរបស់ទារកអ្នកនៅពេលគេទើបបានសំរាលរួចមក។ គឺជាការធ្វើតេសដ៏សាមញ្ញ បានធ្វើដោយយកដំណក់ឈាមកាត់ផ្តាច់ទងផ្ចិតពីសុក បន្ទាប់ពីទារកសំរាលរួចមក។ កំរិតនៃជាតិស្ករក្នុងឈាមពីទងផ្ចិតគឺពិតជាមានសារៈ ប្រយោជន៍យ៉ាងពិសេស គឺបើសិនទារកអ្នកមិនជាស្រួលនៅពេលទើបសំរាលរួច នឹងមានជាជំនួយសំរាប់ផែនការក្នុងការថៃទាំដល់ទារករបស់អ្នកផងដែរ។

### ❖ ការណែនាំដោយសង្ខេបពីដំណាក់កាលនៃការឈឺពោះសំរាលនឹង នឹងការសំរាកទារក

#### ➢ មុនពេលឈឺពោះសំរាលទារកបានចាប់ផ្តើម

- អ្នកអាចបានអនុវត្តន៍នូវរបៀបពុំឲ្យមានការឈឺចុកចាប់ ឬដោយមកពីទារក សំកោងខ្លួនរឹតតឹងណែន " Braxton Hicks " ។
- អ្នកអាចញុំាអាហារ នឹងញុំាទឹកដូចធម្មតាបាន
- មានអារម្មណ៍គិតថាទារកបានកម្រើកបម្រាស់ច្រើនដូចជាធម្មតា
- ចូរឆែកមើល ថាអ្នកពិតជាមានលេខទូរស័ព្ទនៅមន្ទីរពេទ្យច្បាស់ត្រឹមត្រូវដែរ
- អ្នកអាចមានសារធាតុរំអិលកាន់តែកើនច្រើនឡើងនៅក្នុងទ្វារមាស
- កស្បូនរបស់អ្នកនៅបិទជិត ឬបានបើកបន្តិចតែកស្បូននៅកម្រាស់ក្រាស់នៅឡើយ
- អ្នកអាចមានអារម្មណ៍ដោយបានគិតទុកជាមុន ភាពភើបចិត្ត មិនប្រកដក្នុងចិត្ត នឹងមានភាពខ្វាយខ្វល់។



#### ➢ អ្នកអាចស្វែងយល់ថាជាការសំរាកលំហែដ៏ងាយស្រួល បើសិនជាអ្នក ៖

- ដោយការត្រាំក្នុងអាងទឹកក្តៅអ៊ុនៗ (ចូរមើលក្នុងសលាកប័ត្រ "Fact sheets " ពី Water immersion in labour and water birth ។
- ការងូតទឹកក្តៅអ៊ុនៗ
- ចូរដាក់ថង់កំដៅស្អំនៅលើកន្លែងណាដែលអ្នកមានអារម្មណ៍ឈឺចុកចាប់ខ្លាំង
- សុំឲ្យនរណាម្នាក់ធ្វើសរសៃឲ្យ
- ចូរស្តាប់ភ្លេងកំសាន្ត
- ចូរប្រើប្រេងមានក្លិនក្រអូប
- បិទពន្លឺភ្លើងចាំងខ្លាំងនៅក្នុងបន្ទប់របស់អ្នក
- ចូរផ្តង់អារម្មណ៍ទៅលើការដងដង្ហើមរបស់អ្នក
- ការសម្លឹងមើលតែរូបភាព (គឺរូបភាពដ៏ល្អៗជាជំនួយដល់ការសំរាកលំហែកាយ)

#### ➢ តើអ្នកជួយគាំទ្រអាចជួយធ្វើអ្វីដែរ - What your support person can do:

- ការផ្តល់ជួយគាំទ្រដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទ
- ការចាត់ចែងជួយនៅដំណាក់ការចុងក្រោយ ហើយទើបយកអ្នកទៅកាន់មន្ទីរពេទ្យ
- ការយល់នឹងសម្របទៅតាមបំណង ដោយតាមជម្រើសផ្សេងៗរបស់អ្នក
- ការជួយសម្របសម្រួលនៅក្នុងបន្ទប់សម្រាលដោយធ្វើដូចជាទីកន្លែងរបស់អ្នក
- ការធ្វើតាមសញ្ញា (Cues) ពីអ្នកបញ្ញា - ការយល់ដឹងតាមតម្រូវការរបស់អ្នក ដោយយោលទៅតាមពេលវេលាដែលផ្លាស់ប្តូរ។
- ចូររក្សាការស្ងប់ស្ងៀម
- ការផ្តល់ភាពធានានូវថេរភាពដល់អ្នក គឺជាផ្នែកមួយដ៏សំខាន់ដែលគេអាចធ្វើ
- ចូរនិយាយរំលឹកថាអ្នកបានធ្វើល្អណាស់
- ចូរស្តាប់នឹងទទួលតាមបញ្ញាពីឆ្មប ដោយធ្វើការរួមគ្នាផ្តល់ការគាំទ្រដ៏ប្រពៃដល់អ្នក
- ចូររក្សាភាពទទួលខុសត្រូវ ចំពោះការឆ្លើយឬ ហៅទូរស័ព្ទចេញក្រៅ
- ចូរផ្តល់ការគាំទ្រ ទៅតាមផ្នែកផ្សេងៗដែលអ្នកត្រូវការ
- ចូរផ្តង់គោលដៅទៅលើហេតុការដែលកើតមានឡើង នេះជាពេលវេលាដ៏ពិសេស
- ចូរថតរូបមួយចំនួន
- ចូរផ្តល់ពេលវេលាមួយចំនួនដល់គ្រួសារថ្មីនេះ។

- ចូរប្រាប់ទៅឆ្មបឲ្យបានដឹង បើសិនគេត្រូវការសំរាកម្តងម្កាល ឬពេលចេញទៅញ៉ាំអ្វីខាងក្រៅ ឬការសំរាកកាយ។

**វិធីផ្សេងៗសំរាប់ជួយបន្ថយពីការឈឺចុកចាប់ខ្លាំង (Other method of pain relief)**

## ❖ ថ្នាំ នីត្រូស អ៊ុកស៊ីដ (Nitrous Oxide) នឹង ខ្យល់អ៊ុកស៊ីស្សែន (Oxygen)

- ពាក់ម៉ាស់ឲ្យអ្នកដកដង្ហើមស្រូបខ្យល់ Gas ឬ ស៊កបំពង់បឺតតាមមាត់។
- ដោយចាក់ថ្នាំស្រាលឲ្យស្ពឹកមួយរយៈពេលដ៏ខ្លី
- ខ្យល់ Gas មិនបង្កគ្រោះថ្នាក់ ដោយវិធីណាមួយដល់ទារករបស់អ្នកឡើយ
- ស្ត្រីមួយចំនួន មិនសម្របទៅនឹងផ្នែកនេះ ដោយធ្វើឲ្យមានការក្អួតចង្អោរឬអាចធ្វើឲ្យគេស្ងួតមាត់ផងដែរ។

## ❖ ថ្នាំផេធីឌីន (Pethidine)

- ថ្នាំជាតិណារគូទីក (Narcotic) បានផ្តល់ដោយការចាក់ថ្នាំ
- សកម្មភាពដូចជាថ្នាំ សេដាទីវ (Sedative) ធ្វើឲ្យអ្នកងងុយគេង
- ភ័ស្តុតាងថ្មីៗបានបង្ហាញឲ្យឃើញថាថ្នាំ ផេធីឌីន Pethidine) មិនជួយសម្រន់ពីការឈឺចុកចាប់បានល្អនោះឡើយ ដោយបណ្តាលឲ្យមានប្រតិកម្មមិនល្អដល់ម្តាយនឹងទារក សភាពនេះកើតមានច្រើនជាងបានផលប្រយោជន៍ល្អ។

➢ គុណវិបត្តិមួយចំនួនមានចំពោះរូបម្តាយដោយមានរួមគឺ៖

- ការចង់ចង្អោរ ( ថ្នាំលេបកុំឲ្យចង្អោរនឹងត្រូវបានផ្តល់ជូនដើម្បីជួយពីភាពនេះ)។
- មានអារម្មណ៍ងងុយគេងដោយ ឬក៏មិនស្រួលខ្លួន។

➢ គុណវិបត្តិមួយចំនួនមានចំពោះទារកដោយមានរួមគឺ៖

- អាចធ្វើឲ្យទារកមានការពិបាកដកដង្ហើម គឺមានតែមួយរយៈប៉ុណ្ណោះ។
- អាចធ្វើឲ្យទារកមានការពិបាកក្នុងការបឺតជញ្ជក់ ដោយការចាប់ផ្តើមបំបៅដោះទារកដែលអាចបៅបានទាល់តែដល់ 48ម៉ោង ឬ ក៏លើសពីនេះទៀតផង។

## ❖ ការចាក់ម្ជុលបញ្ចូលថ្នាំស្ពឹកទៅក្នុងខួរឆ្អឹងខ្នង (Epidural analgesia)

គឺជាបំពង់តូចមួយបានស៊កបញ្ចូលទៅក្នុងចន្លោះជុំវិញសន្លាក់ទៅដល់ខួរឆ្អឹងខ្នងដែលជាកន្លែងចាក់ថ្នាំស្ពឹក។ ការចាក់បញ្ចូលថ្នាំស្ពឹកនេះគឺត្រូវតែធ្វើដោយវេជ្ជបណ្ឌិតបានទទួលការហ្វឹកហ្វឺន (អ្នកឯកទេសផ្នែកចាក់ថ្នាំសន្លប់នឹងថ្នាំស្ពឹក = **Anaesthetist)**។



## ❖ ការថតរូប (Photography)

ជានិច្ច រយៈពេលសំរាលទារក ឲ្យយកម៉ាស៊ិនថតរូបចូលបាន ដោយការសុំអនុញ្ញាតពីវេជ្ជបណ្ឌិតនឹងឆ្មបដែលជាអ្នកនៅប្រចាំការទីនោះ។

ការប្រើនូវឱបករណ៍ថតវីដេអូ (Video) ឬក៏ ឌីវីឌី (DVD) មិនអនុញ្ញាតឲ្យថត ពេលបង្កើតទារករបស់អ្នក ឬពេលដំណើការអនុវត្តន៍ជួយជាបន្ទាន់ផ្នែកវិជ្ជសាស្រ្តជំនួយ។ សូមគោរពតាមការស្នើនេះដោយប្រាប់ទៅអ្នកជួយគាំទ្រឲ្យបាន យល់ដឹងផងដែរ។

## ❖ ការត្រួតពិនិត្យតាមដានទារករបស់អ្នកនៅពេលឈឺពោះសំរាលទារក

នៅពេលអ្នកឈឺពោះសំរាលទារកគឺជាភាពដ៏សំខាន់ដើម្បីឲ្យបានច្បាស់ថាទារកអ្នកមានសុខភាពល្អ។ បើសិនអ្នកមានសុខភាពល្អដោយការមានផ្ទៃពោះរបស់អ្នកមានសភាពធម្មតា យើងនឹងឆែកមើលទារកនៅពេលឈឺពោះសំរាល ដោយគ្រាន់តែស្តាប់ចង្វាក់បេះដូងទារករាល់ពេលកន្លះម៉ោងម្តងដោយប្រើប្រដាប់ស្ទង់ អុលត្រាសោនដុបភ្លើ (Doppler) ស្រដៀងគ្នាទៅនឹងអ្វីដែលគេបានប្រើនៅពេលដែលពិនិត្យថៃទាំផ្ទៃពោះ។ បើអ្នកឬទារករបស់អ្នកធ្លាប់មានការពិសោធន៍ ឬអាចប្រឈមទៅបទពិសោធន៍ពីបញ្ហានៅពេលមានផ្ទៃពោះ ឬនៅពេលឈឺពោះសំរាលទារក ដូច្នេះអាចមានការត្រួតពិនិត្យមើល ចង្វាក់បេះដូងទារករបស់អ្នក ដោយម៉ាស៊ីនហៅថាការស្ទង់មើលបេះដូង **(CTG)**។ ម៉ាស៊ីននេះផលិតបញ្ចេញនូវកំណត់ហេតុជាបន្តបន្ទាប់ពីចង្វាក់បេះដូងរបស់ទារកអ្នកដោយជំនួយពីក្រុមឆ្មបនឹងវេជ្ជបណ្ឌិតដែលបានត្រួតពិនិត្យយ៉ាងល្អិតល្អន់ពីសុខភាពនឹងសុខមាលភាពរបស់ទារកអ្នក។

ម៉ាស៊ីនស្ទង់មើលបេះដូង (CTG) នេះក៏អាចប្រើសំរាប់ត្រួតពិនិត្យមើលដល់ទារកអ្នក បើអ្នកបានទទួលជំនួយផ្នែកវេជ្ជសាស្រ្តក្នុងការជួយបើកកស្បូនឲ្យឈឺពោះសំរាលទារក ដោយការចាក់ម្ជុលបញ្ចូលថ្នាំស្ពឹកទៅខួរឆ្អឹងខ្នង ឬអ្នកបានសំរាលទារកមុនថ្ងៃកំណត់ ដោយអ្នកមានគម្រោងត្រឡប់ទៅកាន់លំនៅដ្ឋានវិញ។

## ❖ តើខ្ញុំអាចគិតថានៅពេលវះកាត់ផ្ទៃពោះជួយសំរាលទារកយ៉ាងណាដែរ?

## ( What can I expect during a caesarean?)

ករណីភាគច្រើនពេលអ្នកភ្ញាក់ដឹងខ្លួនឡើងនៅពេលវះកាត់ផ្ទៃពោះជួយសំរាលទារករួចហើយ នោះអ្នកមានដៃគូរនៅអង្គុយក្បែរខ្លួនអ្នក។

មុនពេលចាប់ផ្តើមធ្វើការវះកាត់ផ្ទៃពោះជួយសំរាលទារក ការស៊កបញ្ចូលនូវបំពង់បូមដើម្បីបង្ហូរទឹកនោមទៅក្នុងថ្លោកនោមរបស់អ្នក។

អ្នកត្រូវបានគេកោររោមលើថ្ងាសទ្វារមាស ជាទីតាំងបានកំណត់ត្រូវវះកាត់ផ្ទៃពោះជាធម្មតា រោមនៅផ្នែកខាងក្រោមជុំវិញជួរថ្ងាសទ្វារមាសរបស់អ្នក។

អ្នកឯកទេសផ្នែកចាក់ថ្នាំសន្លប់នឹងថ្នាំស្ពឹកបានទប់ឃាំងនៅសន្លាក់ឆ្អឹងខ្នង ឬសំរួលក្នុងការចាក់ថ្នាំស្ពឹកទៅខួរឆ្អឹងខ្នង បើសិនជាអ្នកបានចាក់ថ្នាំរួចម្តងហើយ។

កាលៈទេសៈនៅពេលខ្លះៗ (ជាធម្មតាតែងមានក្នុងស្ថានភាពត្រូវសង្គ្រោះជាបន្ទាន់) ការវះកាត់ផ្ទៃពោះជួយសំរាលទារកបានធ្វើជាទូទៅដោយការចាក់ថ្នាំសន្លំ (អ្នកនឹងគេងលក់)។ បន្ទាប់ពីការវះកាត់ចាប់ផ្តើមមួយរំពេច ទារកនឹងបានសំរាលផងដែរ។

ក្នុងបន្ទប់សំរាប់ការវះកាត់ វេជ្ជបណ្ឌិតនឹងឆ្មបនឹងមើលថែទាំដល់ទារករបស់អ្នក។ បើសិនជាអ្វីៗបានល្អប្រសើហើយ ឆ្មបនឹងជួយគាំទ្រឲ្យអ្នកឪបពីទារករបស់អ្នកដោយដាក់ស្បែកទារកផ្ទប់ផ្ទាល់ទៅនឹងស្បែកម្តាយ ពេលដែលនៅក្នុងបន្ទប់វះកាត់។

ជាទូទៅ អ្នកនឹងត្រូវបានស្ថិតនៅក្នុងបន្ទប់វះកាត់យ៉ាងតិចណាស់មួយម៉ោង។ អ្នកត្រូវចំណាយពេលប្រហែលជា 30នាទីនៅក្នុងបន្ទប់ ទើបនឹងបានស្រួលជាស្បើយមុននឹងចេញទៅកាន់មន្ទីរសំរាប់មាតាសំរាកពេលសំរាលទារកហើយ។

ពេលនោះ គឺសំរាប់អ្នកអាចនឹងបំបៅដោះទាររបស់អ្នកបាន។

ពេលថ្ងៃដំបូង អ្នកមានការជួយបន្ថយការឈឺចុកចាប់ដោយមកពីការចាក់ថ្នាំស្ពឹកទៅខួរឆ្អឹងខ្នង ឬដោយមកពីការចាក់ថ្នាំស្ពឹកនៅតាមសន្លាក់ឆ្អឹងខ្នង។

ភាគច្រើន បន្ទាប់ពីការវះកាត់រួច ក្នុងរយៈពេលដ៏ខ្លី ស្ត្រីបានចាប់ផ្តើមលេបថ្នាំបំបាត់ការឈឺចុកចាប់ដើម្បីការពារកុំឲ្យឈឺ នៅពេលបិទកៅស៊ូស្អិតពីលើមុខរបួស។

អ្នកនឹងបាននៅក្នុងមន្ទីរពេទ្យយ៉ាងយូរ (ជាធម្មតាគឺ 3 យប់ ) ។ ចំពោះពត៌មានជាបន្ថែមទៀត ចូរអាននៅក្នុងសលាកប័ត្ត **“Fact sheets”** ការត្រឡប់ទៅកាន់លំនៅដ្ឋានវិញ ក្រោយពីការវះពោះជួយសំរាលទារករួច។



ដោយពេលខ្លះអាចមានភាពយឺតយ៉ាវទទួលការចាក់ម្ជុលបញ្ចូលថ្នាំស្ពឹកទៅក្នុងខួរឆ្អឹងខ្នងដូចជាត្រូវការរង់ចាំពេលអ្នកឯកទេសផ្នែកចាក់ថ្នាំសន្លប់នឹងថ្នាំស្ពឹកមកដល់ដើម្បីចាប់ធ្វើការអនុវត្តនិតាមនិតិវិធី។

ការចាក់ថ្នាំស្ពឹកទៅក្នុងខួរឆ្អឹងខ្នងធ្វើឲ្យអ្នកស្ពឹកចាប់ពីចង្កេះទៅក្រោម។

ភាគច្រើនស្ត្រី គ្មានភាពឈឺចុកចាប់ស្ទើរតែទាំងស្រុង។

មុនចាប់ផ្តើមអនុវត្តន៍តាមនិតិវិធី អ្នកឯកទេសផ្នែកចាក់ថ្នាំសន្លប់នឹងថ្នាំស្ពឹកបានពន្យល់ពីគុណវិបត្តផ្សេងៗជូនដល់អ្នករួមបញ្ចូលទាំងលទ្ធភាពដូចជា៖

➤ ការឈឺពោះសំរាលមានរយៈពេលដ៏យូរ

- ផ្នែកវេជ្ជសាស្ត្រជំនួយ ដូចជាជួយបង្កើតដោយប្រើប្រដាប់គៀប ឬប្រដាប់បូមទាញក្បាលទារកនឹងការច្រិបកាត់ (ការច្រិបនៅគែមចង្កូរក្រោមទ្វារមាសឲ្យមានទំហំ បើកធំសំរាប់ទារកអ្នកសំរាល) នឹងត្រូវការដេរភ្ជាប់ស្បែកបន្ទាប់ពីសំរាលរួច។
- មិនអាចទប់ទល់នឹងភាពរងារញ្ញាក់ញ័រ
- ការឈឺក្បាលយ៉ាងខ្លាំងបន្ទាប់ពីសំរាលទារករួច (កម្រមានណាស់)
- ភាពទន់នូវកន្លែងលូកស៊កទៅខាងក្នុងទ្វារមាស។

អ្នកនឹងត្រូវបានទទួលការចាក់បន្តក់ទឹកសេរ៉ូម ដើម្បីកុំឲ្យសម្ពាធឈាមរបស់អ្នកធ្លាក់ចុះទាប នឹងនៅតែបន្តការត្រួតតាមមើល ដោយប្រើម៉ាស៊ីនអេឡិចត្រូនិចសំរាប់ស្ទង់នូវចង្វាក់បេះដូងរបស់ទារកអ្នក។

អ្នកត្រូវបានគេស៊កបញ្ចូលនូវបំពង់បូមដើម្បីបង្ហូរទឹកនោមចេញពីថ្លោកនោមរបស់អ្នកផងដែរ ដូច្នេះអ្នកនឹងគ្មានអារម្មណ៍ពីការឈឺនោម ឬមិនបាច់ដើរទៅបង្គន់ឡើយ។

ប្រសិនបើការឈឺពោះសំរាលទារកមានភាពចាប់ផ្តើមបានល្អនោះ អ្នកប្រហែលជាគេសុំដើម្បីពិនិត្យទ្វារមាស ដើម្បីផែកមើលពីភាពបើកកស្បូនរបស់អ្នក មុនពេលជម្រើសយកការចាក់ម្ជុលបញ្ចូលថ្នាំស្ពឹកទៅខួរឆ្អឹងខ្នង។

បើសិនអ្នកតម្រូវដោយធ្វើការវះពោះជួយសំរាលទារក ការចាក់ម្ជុលបញ្ចូលថ្នាំស្ពឹកទៅក្នុងខួរឆ្អឹងខ្នង គឺតែងតែចាក់ថ្នាំស្ពឹកក្នុងការវះកាត់ឲ្យអ្នកផងដែរ។

ចំពោះពត៌មានជាបន្ថែម ចូរអាននៅក្នុងសលាកប័ត្ត ពីការចាក់ម្ជុលបញ្ចូលថ្នាំស្ពឹកទៅក្នុងខួរឆ្អឹងខ្នងសំរាប់ជំនួយបំបាត់ការឈឺចុកចាប់ នៅពេលឈឺពោះសំរាលទារក (Epidural for pain relief in labour) ។

## ❖ ប្រដាប់គៀបនឹងប្រដាប់បូមជួយបង្កើតទារក (Forceps and Ventouse– Vacuum)

ពេលខ្លះ ដោយចាំបាច់សំរាប់ជួយបង្កើតទារកដោយការប្រើដង្កៀបឬប្រដាប់បូម។ ឧបករណ៍ទាំងនេះអាចប្រើបន្ទាប់ពីកស្បូនរបស់អ្នកបានបើកពេញទំហឹង។ មូលហេតុដែលភាគច្រើនមានជាទូទៅគឺ ៖

- ទារកមិនអាចទ្រាំបាននឹងការឈឺពោះសំរាលបាន (លំនាំចង្វាក់បេះដូងរបស់ទារកមិនមានភាពជាធម្មតា)
- ➤ ដំណាក់ការទី 2 នៃការឈឺពោះសំរាលទារកមានភាពជំយ៉ូរ ដែលជាលទ្ធផលអាចមកពី៖ ស្ថានភាពរបស់ម្តាយ (ឧទាហណ៍- ភាពហត់នឿយ)
- ទម្រង់ទីតាំងរបស់ទារក
- ការចាក់ម្ជុលបញ្ចូលថ្នាំស្ពឹកទៅខួរឆ្អឹងខ្នង គឺមានដំណើការយឺតយ៉ូរ
- ម្តាយមានលក្ខណៈផ្នែកវេជ្ជសាស្រ្ត

មុនពេលជួយក្នុងការសំរាលទារក អ្នកត្រូវបានគេស៊កបញ្ចូលនូវបំពង់បូមទៅក្នុងផ្លោកនោមរបស់អ្នកដើម្បីបង្ហូរទឹកនោម។

អ្នកត្រូវការថ្នាំជួយបំបាត់ការឈឺចាប់។ ដោយយោលទៅតាមស្ថានភាព នេះដែលអាចទាក់ទងទៅនឹងការចាក់ថ្នាំស្ពឹក ធ្វើឲ្យស្ពឹកនៅកន្លែងស្បែកចង្អូរក្រោមទ្វារមាសទៅរន្ធគូថដោយចាក់ម្ជុលបញ្ចូលថ្នាំស្ពឹកទៅក្នុងខួរឆ្អឹងខ្នង ឬ រាំងស្ទះនៅសន្លាក់ឆ្អឹងខ្នង។

អ្នកអាចត្រូវការកាត់ច្រិបស្បែកគែមក្រោមជ្រលងទ្វារមាស។ បើសិនបានតម្រូវឲ្យធ្វើដោយបានដេរថ្មេតែបន្តិចប៉ុណ្ណោះបន្ទាប់ពីសំរាលទារកហើយ ជាធម្មតាមានភាពជាសះយ៉ាងល្អប្រសើ ដោយគ្មានបញ្ហាអ្វីឡើយ។

ការជម្រើសយកដង្កៀបឬប្រដាប់បូម ដោយយោលទៅតាមស្ថានភាពខ្លះ នឹងទៅតាមភាពនិយមរបស់វេជ្ជបណ្ឌិត។



## ❖ ប្រដាប់សំរាប់បូមជួយបង្កើតទារក (Ventouse – Vacuum )

គឺជាពែងសំរាប់បូមដែលដាក់គ្របពីលើក្បាលទារក។ ពេលឈឺពោះរឹតកន្ត្រាក់វេជ្ជបណ្ឌិតបានយកប្រដាប់ពែងបូមទាញក្បាលទារក នៅពេលអ្នកខំប្រឹងរម៉ាត់រុញឲ្យទារកសំរាលចេញមកក្រៅ។

## ❖ ប្រដាប់សំរាប់គៀបជួយបង្កើតទារក (Forceps birth)

ប្រដាប់សំរាប់គៀបជួយបង្កើតទារកដែលមានទម្រង់ជាស្លាបព្រាដែកជាឧបករណ៍ដោយរចនាឲ្យស្របទៅនឹងរង្វង់ជុំវិញក្បាលទារក។ នៅពេលឈឺពោះកន្ត្រាកវេជ្ជបណ្ឌិតប្រើប្រដាប់សំរាប់គៀបទាញនៅពេលអ្នកប្រឹងរម៉ាត់ឲ្យទារកសំរាលចេញ។

## ❖ ការវះពោះជួយបង្កើតទារក (Caesarean section)

ការជម្រើសឬបានគម្រោងទុកជាមុនអាចនឹងគិតទុកថាជាភាពចាំបាច់មួយពីព្រោះ៖

- អ្នកបានវះពោះដោយបានសំរាលទារកពីពេលមុន
- អ្នកមានសុកពាំងមាត់ស្បូន (សុកផ្តេកជិតដល់ឬពាំងលើ កស្បូន)
- អ្នកមានករណីផ្នែកវេជ្ជសាស្រ្តធ្វើឲ្យការសំរាលមានហានិភ័យដ៏ធ្ងន់ធ្ងរដល់រូបអ្នកនឹងទារករបស់អ្នកផង។
- ចំនួនហានិភ័យមានខ្លះៗ ដល់ទារកក្នុងការសំរាលតាមទ្វារមាស ឧទារហណ៍៖ ទារកមានទម្រង់បញ្ច្រាស់ (breech) ឬមានទម្រង់មិនជាធម្មតាផ្សេងៗទៀតនៅពេលចុង ក្រោយនៃការមានផ្ទៃពោះរបស់អ្នក។

## ❖ ការវះពោះជួយបង្កើតទារកដោយការសង្គ្រោះជាបន្ទាន់ ជាធម្មតាបានធ្វើប្រសិនជា៖

- ទារកមិនអាចទ្រាំទ្របានទៅនឹងការឈឺពោះសំរាល
- ការឈឺពោះសំរាលមិនអាចមានដំណើរការល្អប្រសើ
- ម្តាយមានការពិបាកខ្លះៗដូចជាការធ្លាក់ឈាមហូរខ្លាំង ឬមានសម្ពាធឈាមលើសខ្លាំងមុនពេលសំរាល (ការលើសឈាម)។